**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# ផ្ញើជូន

ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ឯកឧត្តម ជាទីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ !

ជាបឋម ខ្ញុំនិងភរិយា សូមថ្លែងអំណរគុណដោយក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ចំពោះ ឯកឧត្តម ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងមន្ត្រីរាជការទាំងអស់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលបានជូននូវសព្ទសាធុការពរបវរសួស្តីមហាប្រសើរ ចំពោះរូបខ្ញុំនិងភរិយា ព្រមទាំងក្រុមគ្រួសារ ក្នុងឱកាសចម្រើនជន្មាយុគម្រប់ ៦០ ឈានចូល ៦១ ឆ្នាំ របស់ខ្ញុំ និងពរជ័យសិរីមង្គលទទួលអំណរបុណ្យចូលឆ្នាំថ្មី ឆ្នាំថោះ ត្រីស័ក ព.ស ២៥៥៥ ដែល នឹងឈានចូលមកដល់ក្នុងវេលាដ៏ឆាប់ៗខាងមុខនេះ ។

តបចំពោះសមានចិត្ត និងពាក្យពេចន៍ពរជ័យដ៏មានអត្ថន័យខ្ពង់ខ្ពស់ពីរោះពិសារនេះផងដែរ ខ្ញុំនិង ភរិយា សូមប្រសិទ្ធពរជ័យជូនចំពោះឯកឧត្តម ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងមន្ត្រីរាជការទាំងអស់ នៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សូមទេវតារក្សាឆ្នាំថ្មី ព្រះនាម **កិរិណីទេវី** អភិបាលគ្រងរក្សា ឲ្យបានសមប្រកបតែនឹងពុទ្ធពរទាំងបួនប្រការគឺៈ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបី ឃ្លៀងឃ្លាតឡើយ ។

សូមឯកឧត្តម ទទួលនូវក្តីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំនិងភរិយា ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១១*

**ហ៊ុន សែន**